# របាយការណ៍
# ស្តីពី សិក្ខាសាលាសម្លេងម្ចាស់ឆ្នោត ក្នុងការកំណត់
# តម្រូវការអាទិភាពនៅ ១០០ ឃុំ ដាច់ស្រយាល



ផលិតដោយ

ខុមហ្វ្រែល COMFREL

ខែ មេសា ឆ្នាំ ២០១២

# ឧបត្ថម្ភដោយ

សហភាពអឺរ៉ុប

forum syd

NORWEGIAN PEOPLE'S AID

Oxfam Novib

## ចក្ខុវិស័យ និងបេសកកម្មខុមហ្វ្រែល

ខុមហ្វ្រែល COMFREL

### ចក្ខុវិស័យ

សង្គមប្រជាធិបតេយ្យ មួយដែលដំណើរការប្រជាធិបតេយ្យហូបនីយកម្ម ជាពិសេសរាល់ការបោះឆ្នោត តាមបែបប្រជាធិបតេយ្យត្រូវបានលើកតម្កើង និងមានគុណភាពដែលនាំមកនូវផលប្រយោជន៍ ជូនដល់ប្រជាពលរដ្ឋ។

### បេសកកម្ម

ដើម្បីជួយបង្កើតបរិយាកាសយោគយល់ និងដឹងឮសុះសាយ

**១-** ដល់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌តាមរយៈការបញ្ចុះបញ្ចូល និងការតស៊ូមតិឲ្យមានគម្រោងការគតិយុត្តិសមស្របមួយមានការអប់រំ ផ្តល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិរបស់ពួកគេ និងមានសកម្មភាពអង្កេតឃ្លាំមើល ដែលកាត់បន្ថយភាពមិនប្រក្រតី ហើយផ្តល់ទិន្នន័យអង្កេតដែលអនុញ្ញាតឲ្យមានការវាយតម្លៃមិនលម្អៀង និងជាក់ច្បាស់ចំពោះដំណើរការបោះឆ្នោត។

**២-** សម្រាប់សារសំខាន់ប្រកបដោយអត្ថន័យនៅក្រោយការបោះឆ្នោត តាមរយៈការអប់រំ និងវេទិកាសាធារណៈនានា ដើម្បីជំរុញឲ្យប្រជាពលរដ្ឋចូលរួមក្នុងនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្តការតស៊ូមតិ/បញ្ចុះបញ្ចូល ឲ្យមានកំណែទម្រង់ការបោះឆ្នោត ដែលបង្កើនគណនេយ្យភាពរបស់មន្ត្រីជាប់ឆ្នោតហើយ ផ្តល់ឲ្យនូវទិន្នន័យអង្កេតដែលនាំទៅដល់ការវាយតម្លៃមិនលម្អៀង និងជាក់ច្បាស់ស្តីពីការបំពេញការងារតាមកម្មវិធីនយោបាយរបស់មន្ត្រីជាប់ឆ្នោត។

# មាតិកា


១-សេចក្តីផ្តើម ..................................................១
២-គោលបំណង..................................................១
៣-សង្ខេបវិធីសាស្ត្រ..................................................២
៤-លទ្ធផលសិក្ខាសាលា..................................................៣
    ៤.១.សមាសភាពអ្នកចូលរួម ..................................................៣
    ៤.២.តម្រូវការអាទិភាព..................................................៣
        ៤.២.១.ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត..................................................៤
        ៤.២.២.អប់រំ និងសុខាភិបាល..................................................៥
        ៤.២.៣.ដីធ្លី..................................................៧
        ៤.២.៤.ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន..................................................៧
        ៤.២.៥.រដ្ឋបាល និងសន្តិសុខ..................................................៧
        ៤.២.៦.ការសាងសង់ប៉ុស្តិ៍នគរបាល រដ្ឋបាល សាលាឃុំ និងសាលាប្រជុំភូមិ...............៨
        ៤.២.៧.ផ្សេងៗ..................................................៨
    ៤.៣.ការសន្យារបស់គណបក្សនយោបាយក្នុងសិក្ខាសាលា..................................................១០
    ៤.៤.ការជ្រើសរើសអ្នកស្ម័គ្រចិត្តមូលដ្ឋាន..................................................១៥
៥-ការផ្សព្វផ្សាយលទ្ធផលសិក្ខាសាលា..................................................១៥
៦-ការតាមដាន..................................................១៥
៧-ឧបសម្ព័ន្ធ
    ឧបសម្ព័ន្ធ១ ៖ ឈ្មោះឃុំ ស្រុក ខេត្ត រៀបចំសិក្ខាសាលា..................................................១៦
    ឧបសម្ព័ន្ធ២ ៖ កម្មវិធីសិក្ខាសាលា..................................................២៦
    ឧបសម្ព័ន្ធ៣ ៖ វិធីសាស្ត្រ..................................................២៧

# ១-សេចក្តីផ្តើម

ក្រោយការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដែលបានចាប់ផ្តើមតាមរយៈក្របខណ្ឌច្បាប់ស្តីពីការ គ្រប់គ្រងឃុំ-សង្កាត់។ ផ្អែកលើក្របខណ្ឌច្បាប់នេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) បានដាក់ចេញនូវគោលការណ៍ពាក់ព័ន្ធ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ-សង្កាត់ជាដើម ដើម្បីជម្រុញឲ្យមានការអនុវត្តប្រព័ន្ធវិមជ្ឈការ វិសហមជ្ឈការ និងអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិឲ្យប្រកបដោយប្រសិទ្ធិភាព។

ទោះបីជាមានផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ-សង្កាត់ ដើម្បីស្វែងយល់ពីតម្រូវការរបស់ប្រជាពលរដ្ឋពិតមែន ក៏នៅតែមានសេវាកម្មមួយចំនួន ប្រជាពលរដ្ឋនៅឃុំដាច់ស្រយាល មិនទាន់ទទួលបានគ្រប់វិស័យនៅឡើយ ជាពិសេសម្ចាស់ឆ្នោតពិបាកក្នុងការវាយតម្លៃ និងតាមដានពីការអនុវត្តផែនការ និងកម្មវិធីទាំងនោះ។

ដោយសង្កេតឃើញបញ្ហានេះ គណៈកម្មាធិការខុមហ្វ្រែល ដោយមានការឧបត្ថម្ភគាំទ្រចំបងសហភាពអឺរ៉ុប (EU) និងម្ចាស់ជំនួយផ្សេងទៀតដូចជា OXFAM NOVIB, NPA , Forum Syd បានរៀបចំសិក្ខាសាលា "*សំលេងម្ចាស់ឆ្នោត ស្តីពី ការកំណត់តម្រូវការជាអាទិភាព នៅឃុំដាច់ស្រយាល*" ។

# ២-គោលបំណង

សិក្ខាសាលានេះ ជាគំនិតផ្តួចផ្តើម ក្នុងគោលបំណងឲ្យម្ចាស់ឆ្នោត និងអ្នកដឹកនាំមូលដ្ឋាន ឬតំណាងគណបក្សនយោបាយនៅឃុំដាច់ស្រយាលនីមួយៗ ៖

១- យល់ដឹងអំពីសិទ្ធិ តួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោត ក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។

២- ផ្តល់ឱកាសឲ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ/សង្កាត់របស់ខ្លួន។

៣- តម្រូវការជាអាទិភាពក្នុងឃុំដាច់ស្រយាល នឹងត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឲ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន ជម្រុញការអនុវត្តរបស់ក្រុមប្រឹក្សា

ឃុំ/សង្កាត់ ព្រមទាំងដាក់បញ្ចូលតម្រូវការអាទិភាពទាំងនោះក្នុងកម្មវិធីនយោបាយរបស់គណបក្ស សម្រាប់ការបោះឆ្នោតឃុំ ឆ្នាំ២០១២។

# ៣-សង្ខេបវិធីសាស្រ្ត[1]

ឃុំចំនួន១០០ នៅ១៨ខេត្ត ត្រូវបានជ្រើសរើសឡើង ក្នុងចំណោមឃុំដាច់ស្រយាលចំនួន៣៥០ឃុំ នៅទូទាំងប្រទេសកម្ពុជា ដើម្បីរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោត ស្ដីពី ការកំណត់តម្រូវការអាទិភាព នៅឃុំដាច់ស្រយាល ក្នុងឆ្នាំ២០១១-២០១២នេះ។ ឃុំដាច់ស្រយាលមានន័យថា ឆ្ងាយពីទីប្រជុំជន ខ្វះផ្លូវ ឬលំបាកធ្វើដំណើរដើម្បីទៅដល់គ្មានប្រព័ន្ធផ្សព្វផ្សាយ, និងភាគច្រើនជាឃុំ/សង្កាត់របស់ជនជាតិដើមភាគតិច។ អ្នកចូលរួមជាម្ចាស់ឆ្នោតប្រមាណ **៥៨០៧**នាក់ ក្នុងនោះ **១៩៨៧**នាក់ជាស្ត្រី រួមមានតំណាងសហគមន៍ តំណាងអង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ មេភូមិ បានបែងចែកក្រុមពិភាក្សាជា ៣ក្រុម ដើម្បីពិភាក្សាកំណត់តម្រូវការតាមឃុំនីមួយៗ។ ការកំណត់ ឬអញ្ជើញអ្នកចូលរួម ក្រុមការងារខុមហ្វ្រែលខេត្តបានសហការជាមួយអាជ្ញាធរ អង្គការសហគមន៍មូលដ្ឋាន និងបណ្ដាញខុមហ្វ្រែល ដើម្បីជ្រើសរើសអ្នកចូលរួម ដូចជា អាចចេះអាន ឬសរសេរអក្សរខ្មែរ ហើយត្រូវមកពីគ្រប់ភូមិក្នុងឃុំ។ ម្យ៉ាងវិញទៀត តំណាងគណបក្សនយោបាយនៅតាមឃុំ នីមួយៗរួមទាំងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ និងមេភូមិ ក៏បានអញ្ជើញឲ្យចូលរួម និងពិភាក្សា ការគាំទ្រ នូវតម្រូវការជាអាទិភាពដែលអ្នកចូលរួមទាំងអស់បានកំណត់ និងបោះឆ្នោតគាំទ្រផងដែរ។

ខាងក្រោមនេះជាការសង្ខេបវិធីសាស្រ្តក្នុងការកំណត់តម្រូវការអាទិភាព៖

**ជំហានទី១៖** បែងចែកក្រុមពិភាក្សាជាបីក្រុម ដោយដាក់ឲ្យអ្នកចូលរួមមកពីភូមិផ្សេងៗគ្នា បន្ទាប់ក្រុមនីមួយៗត្រូវពិភាក្សាគ្នា ស្វែងរក អ្វីដែលជាតម្រូវការក្នុងមូលដ្ឋានផ្ទាល់ ។

**ជំហានទី២៖** តាមក្រុមពិភាក្សានីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសយកតែ ៥ តម្រូវការតែប៉ុណ្ណោះក្នុងមួយក្រុម ដោយគិតថាអាទិភាពជាងគេ។

[1] សេចក្ដីណែនាំ ស្ដីពី ការរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោត ក្នុងការកំណត់តម្រូវការអាទិភាពនៅឃុំដាច់ស្រយាល

**ជំហានទី៣៖** ចាប់បញ្ចូលតម្រូវការតាមផ្នែក រួចតម្រូវឲ្យប្រជាពលរដ្ឋចូលរួមបោះឆ្នោតជ្រើសរើសយកតែ ៥ អាទិភាពប៉ុណ្ណោះ។ ជាចុងបញ្ចប់សមាជិកត្រូវបោះឆ្នោតគាំទ្រម្តងទៀតនូវលទ្ធផល។



ប្រជាពលរដ្ឋក្នុង ឃុំគោគរមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កំពុងពិភាក្សា ដើម្បីកំណត់តម្រូវ ការជាអាទិភាពកាល ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១។

# ៤-លទ្ធផលសិក្ខាសាលា

## ៤.១.សមាសភាពអ្នកចូលរួម

អ្នកចូលរួមសិក្ខាសាលា(សិក្ខាកាម) សរុបទាំង១០០ ឃុំ សង្កាត់មានចំនួន **៥៨០៧**នាក់ ក្នុងនោះ **១៩៨៧**នាក់ជាស្ត្រី ដែលស្មើនឹង **៣៤%** ។ សិក្ខាកាមចូលរួមជា ជនជាតិដើមភាគតិច (កួយ ព្នងគ្រឹង ចារាយ ....) **៧៤៣**នាក់ ស្មើ **១៣%** យុវជន (អាយុពី១៨ ដល់៣៥) **៨៩០**នាក់ដែលស្មើ **១៥.៣%** , ប្រជាពលរដ្ឋធម្មតា **១៥២៨**នាក់ តំណាងសហគមន៍ និងសង្គមស៊ីវិល **២៦៣**នាក់ មេភូមិ ឃុំ **៧៥៨**នាក់ ក្រុមប្រឹក្សាឃុំ**៣៦៦**នាក់ ក្រុមប្រឹក្សាស្រុក **៦**នាក់ និងបណ្តាញអង្គការខុមប្រែល **២៤២**នាក់។

## ៤.២.តម្រូវការអាទិភាព

លទ្ធផលខាងក្រោមគឺ ជាបណ្តុំតម្រូវការជាអាទិភាព ដោយម្ចាស់ឆ្នោតនៅក្នុងឃុំដាច់ស្រយាលទាំង១០០ឃុំ ទៅតាមផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ/សង្កាត់ ។

### ៤.២.១.ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

- ស្នើសុំជួសជុលផ្លូវលំចំនួន១១៥ខ្សែ ស្មើនឹងប្រវែងសរុប ៤៤៥គីឡូម៉ែត្រ នៅក្នុងឃុំចំនួន ៨៤ សុំសាងសង់ផ្លូវថ្មី ដែលជាប្រភេទផ្លូវលំ ចំនួន ២៤០ខ្សែ ស្មើនឹងប្រវែងសរុប ១,៣៦៥ គីឡូម៉ែត្រ នៅក្នុងឃុំចំនួន ៧៥ឃុំ។
- ស្នើសុំជួសជុលផ្លូវជាប្រភេទផ្លូវកៅស៊ូ ចំនួន៥ខ្សែ ស្មើនឹងប្រវែងសរុប ១២.៣៥គីឡូម៉ែត្រ ការស្នើសុំនេះមាន ៣ឃុំ គឺ ឃុំព្រែកកណ្តៀងនៃខេត្តព្រៃវែង ឃុំផ្សារដែក និងឃុំថ្មគរនៃខេត្តកណ្តាល។ សុំសាងសង់ផ្លូវថ្មីជាប្រភេទផ្លូវកៅស៊ូ ចំនួន ១៩ខ្សែ ស្មើនឹងប្រវែងសរុប ១៥៩គីឡូម៉ែត្រ ដែលការស្នើសុំនេះមានចំនួន១១ ឃុំ/សង្កាត់។
- ស្នើសុំសាងសង់ស្ពានចំនួនសរុប ១៨៥កន្លែង ស្មើនឹង ៥១ឃុំ/សង្កាត់ ,ស្នើសុំជួសជុលស្ពានចំនួន២ កន្លែង គឺឃុំបេងនៃខេត្តឧត្តរមានជ័យ និងឃុំធ្មានៃខេត្តព្រះវិហារ។
- ស្នើសុំជីកស្រះទឹកចំនួនសរុប ៧៩កន្លែង នៅក្នុង ១៥ឃុំ/សង្កាត់ ដែលក្នុងនោះមាន៦កន្លែងស្នើសុំស្តារស្រះ គឺ ឃុំស្វាយចចិបនៃខេត្តកំពង់ស្ពឺ និងឃុំពោធិនៃខេត្តព្រះវិហារ។
- ស្នើសុំសាងសង់អាងស្តុកទឹកតូចៗ ចំនួនសរុប ៨០២អាង នៅពីរឃុំ គឺឃុំកោះស្រឡាយនៃខេត្តស្ទឹងត្រែង និងឃុំផាន់ញើមនៃខេត្តកំពង់ធំ។ ស្នើសុំធុងចម្រោះទឹក ចំនួនសរុប ១០៥០០ធុង នៅ១៩ឃុំ ។
- ស្នើសុំជួសជុលទំនប់ទឹក/ទ្វារទឹក/ស្ថានីយបូមទឹកចំនួនសរុប ៣៦កន្លែង ស្មើនឹងប្រវែងសរុប ២៧.៣៦គីឡូម៉ែត្រ នៅក្នុងឃុំចំនួន ១១ឃុំ និងសុំសាងសង់ទំនប់/ទ្វារទឹក/ស្ថានីយបូមទឹកថ្មី ចំនួនសរុប ៣៦កន្លែង មានប្រវែងសរុប ១២.១៤គីឡូម៉ែត្រ នៅឃុំចំនួន១៥។
- ស្នើសុំសាងសង់ប្រឡាយទឹកថ្មីចំនួនសរុប ២៩ខ្សែ ដែលមានប្រវែងសរុប ១៦៨គីឡូម៉ែត្រ នៅឃុំចំនួន ១១ឃុំ។ សុំស្តារប្រឡាយទឹកចំនួនសរុប ៣២ខ្សែ ស្មើនឹងប្រវែងសរុប១២០ គីឡូម៉ែត្រ នៅឃុំចំនួន១៧ឃុំ។
- ស្នើសុំដាក់លូចំនួនសរុប ៨៩១កន្លែង នៅក្នុងឃុំចំនួន ៤៨ឃុំ និងដាក់លូរំដោះទឹក ចំនួន ១៥កង់ នៅឃុំស្វាយចចិបនៃខេត្តកំពង់ស្ពឺ។
- ស្នើសុំជីកអណ្តូងលូថ្មីសរុប ២៣៥៣ អណ្តូង នៅក្នុងឃុំចំនួន ៣១ឃុំ និងស្តារអណ្តូងលូ ចំនួន ២អណ្តូង នៅក្នុងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ,ជីកអណ្តូងស្នប់ថ្មី ចំនួនសរុប ១២១២ អណ្តូង នៅក្នុងឃុំចំនួន ២៨ឃុំ និងស្តារ ៣អណ្តូង នៅក្នុងឃុំបរខាំ ស្រុកអូរយ៉ាដាវ ខេត្តរតនៈគិរី។

- ស្នើសុំសាងសង់បង្គន់អនាម័យថ្មីចំនួនសរុប ៣៨០៨១បង្គន់ នៅឃុំចំនួន ៦៦ឃុំ ក្នុងនោះរួមមាន៧៨៧បង្គន់ សុំតែសំភារៈយកមកសាងសង់ខ្លួនឯង គឺមានតែ២ឃុំប៉ុណ្ណោះ គឺឃុំអូរសារាយនៃខេត្តតាកែវ, ឃុំជីខក្រោមនៃខេត្តកោះកុង។

## ៤.២.២.អប់រំ និងសុខាភិបាល

- ស្នើសុំសាងសង់សាលារៀន៖
  - **សាលាមត្តេយ្យ** ៖ ចំនួនសរុប ២០ខ្នង, គ្រូ ២០នាក់ សំភារៈ ៨ករណី រួមមានទីចាត់ការបណ្ណាល័យ តុកៅអី នៅក្នុងឃុំចំនួន៨ គឺឃុំ ព្រះរំកិលនៃខេត្តស្ទឹងត្រែង, ឃុំ ព្រះឃ្លាំងនៃខេត្តព្រះវិហារ ឃុំអូរជ្រៅនៃ ខេត្តបន្ទាយមានជ័យ ឃុំស្រែអង្គ្រងនៃខេត្តរតនៈគិរី ឃុំលំទងនៃខេត្តឧត្តរមានជ័យ ឃុំព្រីងធំនៃខេត្តព្រះវិហារ ឃុំកំពង់រាបនៃខេត្តតាកែវ ឃុំចាន់មូលនៃខេត្តកំពង់ចាម។
  - **សាលាបឋមសិក្សា** ៖ ចំនួនសរុប ៧២ខ្នង, ជួសជុល ១ខ្នង, គ្រូ ៣៥១ នាក់, សំភារៈ ៨០ករណី ក្នុងនោះរួមមានផ្ទះគ្រូស្នាក់នៅ១៨ករណី សិស្ស១ករណី និងបណ្ណាល័យ២ករណី នៅក្នុងឃុំចំនួន ៣៥ឃុំ។
  - **សាលាអនុវិទ្យាល័យ**៖ ចំនួនសរុប ២៧ខ្នង ដែលក្នុងនោះ រួមមាន ១ករណីជាសាលាបណ្តែតទឹក គ្រូ៦៨នាក់ សំភារៈ៩ករណី ក្នុងនោះរួមមានផ្ទះគ្រូស្នាក់នៅអន្តេវាសិកដ្ឋានបណ្ណាល័យ ទីចាត់ការ នៅក្នុងឃុំចំនួន១៩ឃុំ។
  - **សាលាវិទ្យាល័យ**៖ ចំនួនសរុប ៣ខ្នង នៅក្នុងឃុំចំនួន ៣ឃុំ គឺឃុំសំអាង ឃុំតាវែង ឃុំកោះជីវាំង សុំគ្រូ ២៣នាក់ នៅក្នុងឃុំចំនួន៣ឃុំគឺ ឃុំសំអាងនៃខេត្តស្ទឹងត្រែង ឃុំជីខក្រោមនៃខេត្តកោះកុង ឃុំតាវែងលើនៃខេត្តរតនៈគិរី សុំសំភារៈ ៦ករណី ក្នុងនោះរួមមានផ្ទះគ្រូស្នាក់នៅ ២ករណី វិទ្យាល័យ សំភារៈ ៦ករណី នៅក្នុងឃុំចំនួន៥ឃុំ គឺឃុំសំអាងនៃខេត្តស្ទឹងត្រែង ឃុំបាក់អន្លូងនៃខេត្តឧត្តរមានជ័យ ឃុំកំពង់ឃ្លាំងនៃខេត្តព្រះវិហារ ឃុំតាវែងលើនៃខេត្តរតនៈគិរី ឃុំកោះជីវាំងនៃខេត្តបាត់ដំបង។

- ស្នើសុំធ្វើរបងសាលារៀន/ក្លោងទ្វារចំនួនសរុប ១១កន្លែង ដែលមានប្រវែងសរុប ២៨៩០ ម៉ែត្រ នៅក្នុងឃុំចំនួន៥ឃុំ គឺឃុំសំអាងនៃខេត្តស្ទឹងត្រែង ឃុំក្បាលដំរីនៃខេត្តក្រចេះ ឃុំខ្ទុំក្រាំងនៃខេត្តកំពង់ស្ពឺ ឃុំអូរជ្រៅនៃខេត្តបន្ទាយមានជ័យ, ឃុំត្បែងនៃខេត្តសៀមរាប ។
- ស្នើសុំគ្រូបង្រៀនអក្ខរកម្ម ចំនួន៦នាក់នៅក្នុងឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង ។
- ស្នើសុំផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រនៅក្នុងសហគមន៍ចំនួន ៤ករណី គឺឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប និងឃុំបាក់អន្លូង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
- ស្នើសុំសាងសង់ប៉ុស្តិ៍សុខភាព ចំនួនសរុប ៥៧ខ្នង ជួសជុល ៩ ខ្នង នៅក្នុងឃុំចំនួន២៧ឃុំ ពេទ្យឆ្មប១៩នាក់ នៅក្នុង ១១ឃុំ ពេទ្យទូទៅ៣២នាក់ នៅក្នុងឃុំចំនួន១៣ឃុំ ពេទ្យរបេងភ្នែក-ច្រមុះ/បំពង់ក-កុមារ៧៧នាក់ នៅក្នុង ១៥ឃុំ ថ្នាំពេទ្យ ៤ករណី នៅក្នុងឃុំចំនួន ៤គឺឃុំសេដា ឃុំបរខាំ ឃុំតាវែងលើ ឃុំប៉ាតេនៃខេត្តរតនៈគិរី, បរិក្ខារពេទ្យ៩ករណី នៅក្នុងឃុំចំនួន៩ឃុំ គឺឃុំស្រែអង្គ្រង ឃុំសាមគ្គី ឃុំប៉ាតាង ឃុំបរខាំ ឃុំតាវែងលើ ឃុំប៉ាតេ ឃុំប៉ូយ ឃុំកិះចុងនៃខេត្តរតនៈគិរី ឃុំបឹងចារនៃខេត្តក្រចេះ។
- ស្នើសុំសាងសង់មណ្ឌលសុខភាព ចំនួនសរុប ២៧ខ្នង ជួសជុល១ខ្នង នៅក្នុង ២៣ឃុំ អាគាររង់ចាំ ១ខ្នង នៅឃុំគោករមៀតនៃខេត្តបន្ទាយមានជ័យ ពេទ្យឆ្មប២៥នាក់ នៅ ១២ឃុំ, ពេទ្យកុមារ១៨នាក់ នៅ ៧ឃុំ ពេទ្យទូទៅ៥២នាក់ នៅ១៦ឃុំ ពេទ្យរបេង-ភ្នែក-ច្រមុះ/បំពង់ក-២១នាក់ នៅ ៦ ឃុំ ថ្នាំពេទ្យ ៩ករណី នៅ៩ ឃុំ គឺឃុំបាក់អន្លូងឧត្តរមានជ័យ ឃុំកំពង់ឃ្លាំងនៃខេត្តព្រះវិហារ ឃុំអង្គកែវនៃខេត្តតាកែវ ឃុំកោះកាពិនៃខេត្តកោះកុង ឃុំយ៉ាទុងនៃខេត្តរតនៈគិរី ឃុំកំពង់ចាមនៃខេត្តក្រចេះ ឃុំអំពិលទឹកនៃខេត្តកំពង់ឆ្នាំង, ឃុំញ៉ាងនៃខេត្តរតនៈគិរី ឃុំល្វាក្រាំងនៃខេត្តសៀមរាប បរិក្ខារពេទ្យ១៨ករណី នៅ១៨ឃុំ យានយន្ត ៩ករណី នៅ៨ឃុំគឺ ឃុំសំពោងសែននៃខេត្តកំពង់ឆ្នាំង ឃុំបាក់អន្លូងនៃខេត្តឧត្តរមានជ័យ ឃុំកំពង់ឃ្លាំងនៃខេត្តព្រះវិហារ ឃុំតាសៀម ឃុំត្បែង ឃុំស្រែណូយ ឃុំល្វាក្រាំង និងឃុំល្វែងឬស្សីនៃខេត្តសៀមរាប។
- ស្នើសុំមុងជ្រលក់ថ្នាំសរុបចំនួន ១៥៥៩មុង នៅក្នុងឃុំចំនួន២ឃុំគឺ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ និងឃុំប៉ាតាង ស្រុកលំផាត់ ខេត្តរតនៈគិរី។

### ៤.២.៣.ដីធ្លី

- ស្នើសុំឲ្យដោះស្រាយទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋ ជាមួយក្រុមហ៊ុន ក្រុមហ៊ុនអភិវឌ្ឍន៍ និងអ្នកមានអំណាច សរុបចំនួន ៩១ករណី នៅក្នុងឃុំចំនួន ២២ឃុំ។
- ស្នើសុំផ្ដល់ដីសម្បទានសង្គមកិច្ច
សម្រាប់លំនៅដ្ឋាន ចំនួនសរុប ៧ករណី នៅក្នុងឃុំចំនួន៧ឃុំគឺ ឃុំរមណីនៃខេត្តព្រះវិហារ ឃុំទំរីងនៃខេត្តកំពង់ធំ ឃុំក្បាលដំរីនៃខេត្តក្រចេះ ឃុំកំពង់ចាមនៃខេត្តក្រចេះ ឃុំសេដានៃខេត្តរតនៈគិរី ឃុំ២ធ្នូនៃខេត្តក្រចេះ ឃុំញ៉ាងនៃខេត្តរតនៈគិរី និងសម្រាប់កសិកម្មសរុប ១៣។ ចំនួន ១៣ករណី នៅក្នុងឃុំចំនួន១៣គឺឃុំទំរីងនៃខេត្តកំពង់ធំ ឃុំក្បាលដំរីនៃខេត្តក្រចេះ ឃុំយ៉ាទុងនៃខេត្តរតនៈគិរី ឃុំប្រម៉ោយនៃខេត្តពោធិសាត់ ឃុំសេដានៃខេត្តរតនៈគិរី ឃុំលំទងនៃខេត្តឧត្តរមានជ័យ ឃុំ២ធ្នូនៃខេត្តក្រចេះ ឃុំកោះជីវាំងនៃខេត្តបាត់ដំបង ឃុំញ៉ាងនៃខេត្តរតនៈគិរី ឃុំក្រយានៃខេត្តកំពង់ធំ ឃុំភ្ញីមាសនៃខេត្តកោះកុង ឃុំជ្រោយប្រស់នៃខេត្តកោះកុង។

### ៤.២.៤.ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

- ស្នើសុំទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ/ការការពារធនធានធម្មជាតិ/ទំនប់វារីអគ្គិសនី សរុបចំនួន ១៥ករណីនៅក្នុងឃុំចំនួន ១៣ឃុំ។
- ស្នើសុំទប់ស្កាត់ការនេសាទខុសច្បាប់ចំនួន ១០ករណី នៅក្នុងឃុំចំនួន ៩ឃុំ គឺឃុំតាលាស់នៃខេត្តបាត់ដំបង ឃុំទឹកវិល និងឃុំថ្មគរនៃខេត្តកណ្ដាល ឃុំដំរីពួននៃខេត្តព្រៃវែង ឃុំផ្សារដែកនៃខេត្តកណ្ដាល ឃុំសំបូរនៃខេត្តបន្ទាយមានជ័យ ឃុំលើកដែកនៃខេត្តកណ្ដាល ឃុំព្រែកកណ្ដៀងនៃខេត្តព្រៃវែង ឃុំភ្ញីមាសនៃខេត្តកោះកុង។
- ស្នើសុំបង្កើតសហគមន៍ នេសាទ សហគមន៍ព្រៃឈើ និងសហគមន៍អូរប៉េសរុបចំនួន ១៣ នៅក្នុងឃុំចំនួន ៩ឃុំ គឺឃុំរមណីនៃខេត្តព្រះវិហារ ឃុំតឹន និងឃុំលុងឃុងនៃខេត្តរតនៈគិរី ឃុំពោធិ៍ ឃុំព្រីងធំ និងឃុំរក្សានៃខេត្តព្រះវិហារ ឃុំតាវែងលើនៃខេត្តរតនៈគិរី ឃុំកោះជីវាំងនៃខេត្តបាត់ដំបង ឃុំក្រាំងស្គារនៃខេត្តកំពង់ឆ្នាំង ឃុំកាឡែងនៃខេត្តរតនៈគិរី ឃុំជ្រោយប្រស់នៃខេត្តកោះកុង។

### ៤.២.៥.រដ្ឋបាល និងសន្តិសុខ

- ស្នើសុំឲ្យរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ពីអំពើ លួច ឆក់ ប្លន់ ក្មេងទំនើងសរុបចំនួន ៦ករណី នៅក្នុងឃុំចំនួន៦គឺ ឃុំទឹកវិលនៃខេត្តកណ្ដាល ឃុំជាំក្រវៀននៃខេត្តកំពង់ចាម ឃុំដំរីផុងនៃ

ខេត្តក្រចេះ ឃុំពាមជីលាំងនៃខេត្តកំពង់ចាម ឃុំផ្លូវទូកនៃខេត្តកំពង់ឆ្នាំង ឃុំបឹងចារនៃខេត្តក្រចេះ។

- ស្នើសុំពន្លឿនការធ្វើអត្តសញ្ញាណបណ្ណ័ចំនួនសរុប ៧ករណី នៅក្នុងឃុំចំនួន ៧គឺឃុំស្វាយចចិ និងឃុំខ្ចុំក្រាំងនៃខេត្តកំពង់ស្ពឺ ឃុំជាំក្រវៀន និងឃុំពាមជីលាំងណាសខេត្តកំពង់ចាម ឃុំផ្លូវទូកនៃខេត្តកំពង់ឆ្នាំង ឃុំបូករូង និងឃុំត្រពាំងជោរនៃខេត្តកំពង់ស្ពឺ ។
- ស្នើសុំចុះបញ្ជីដីធ្លី ៩ករណី នៅក្នុងឃុំចំនួន ៧ឃុំ គឺឃុំភ្ញីមាសនៃខេត្តកោះកុង ឃុំកំពង់ដំរីនៃខេត្តក្រចេះ ឃុំដាក់ដាំនៃខេត្តមណ្ឌលគិរី ឃុំក្រាំងស្គារនៃខេត្តកំពង់ឆ្នាំង ឃុំស្រែខ្ទុមនៃខេត្តមណ្ឌលគិរី ឃុំជីខក្រោមនៃខេត្តកោះកុង ឃុំពាមជីលាំងនៃខេត្តកំពង់ចាម។

### ៤.២.៦.សាងសង់ប៉ុស្តិ៍នគរបាល រដ្ឋបាល សាលាឃុំ និងសាលាប្រជុំភូមិ

- ស្នើសុំសាងសង់ប៉ុស្តិ៍នគបាល រដ្ឋបាលឃុំសរុប ចំនួន ៩ករណី នៅក្នុងឃុំចំនួន ៩ឃុំ គឺ ឃុំទឹកវិលនៃខេត្តកណ្តាល ឃុំអូរជ្រៅនៃខេត្តបន្ទាយមានជ័យ ឃុំផ្សារដែកនៃខេត្តកណ្តាល ឃុំក្រសាំង និងឃុំបេងនៃខេត្តឧត្តរមានជ័យ ឃុំបឹងបេងបន្ទាយមានជ័យ ឃុំញ៉ាងរតនៈគិរី ឃុំប្រឡាយនៃខេត្តកោះកុង ឃុំសំបូរនៃខេត្តបន្ទាយមានជ័យ។
- ស្នើសុំសាងសង់សាលាឃុំ យកស្តង់ដាក្រសួងមហាផ្ទៃសរុប ចំនួន ១២ករណី នៅ ១២ឃុំ បញ្ចុះតម្លៃសេវាសាធារណៈដូចជាការធ្វើសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ជាដើម សរុបចំនួន២ករណី នៅឃុំជីខរក្រោមនៃខេត្តកោះកុង និងឃុំចាន់មូលនៃខេត្តកំពងចាម ។
- ស្នើសុំសាងសង់សាលាប្រជុំភូមិសរុបចំនួន ៧កន្លែង នៅក្នុងឃុំ ចំនួន៦ គឺឃុំខ្ចុំក្រាំងនៃខេត្តកំពង់ស្ពឺ ឃុំលុងយុងរតនៈគិរី ឃុំស្រែខ្ទុំនៃខេត្តមណ្ឌលគិរី ឃុំតាវែងលើនៃខេត្តរតនៈគិរី, ឃុំអូរសោមនៃខេត្តពោសាធិសាត់ ឃុំប៉ាតេនៃខេត្តរតនៈគិរី។

### ៤.២.៧.ផ្សេងៗ

- ស្នើសុំសាងសង់សាលាឆាន់ ចំនួន ២កន្លែងនៅឃុំស្រែអង្គ្រងនៃខេត្តរតនៈគិរី ឃុំរាំងទិលនៃខេត្តពោធិសាត់ ព្រះវិហារចំនួន ២កន្លែងគឺ ឃុំរាំងទិលនៃខេត្តពោធិសាត់ ឃុំព្រីងធំនៃខេត្តព្រះវិហារ ឈាបនដ្ឋាន ចំនួន៤កន្លែង នៅឃុំកោះជីវាំងនៃខេត្តបាត់ដំបង និងចាក់ដីគ្រឺះវិហារ ២កន្លែង នៅឃុំក្បាលដំរីនៃខេត្តក្រចេះ ឃុំចាន់មូលនៃខេត្តកំពង់ចាម។
- ស្នើសុំឲ្យមានការអន្តរាគមន៍បញ្ចុះតម្លៃប្រេងសរុបចំនួ៩ ករណី នៅក្នុងឃុំចំនួន ៨ឃុំ គឺឃុំបន្ទាយចក្រីនៃខេត្តព្រៃវែង ឃុំអូរជ្រៅ និងឃុំបឹងបេងនៃខេត្តបន្ទាយមានជ័យ ឃុំដំបូករូងនៃខេត្តកំពង់ស្ពឺ ឃុំព្រៃកកណ្តៀងនៃខេត្តព្រៃវែង ឃុំឈើខ្មៅនៃខេត្តកណ្តាល ឃុំស្រែចារនៃខេត្តក្រចេះ។

- ស្នើសុំបើកវគ្គបណ្តុះបណ្តាលផ្នែកច្បាប់នានា ដូចជា ក្រមព្រហ្មទណ្ឌ ចរាចរណ៍ ភូមិបាល សុខភាពអនាម័យ ច្បាប់ការងារ ការប្រែប្រួលអាកាសធាតុ គ្រុនឈាម សរុបចំនួន ៣៥ ករណី នៅក្នុងឃុំចំនួន ២៨ ឃុំ។
- ស្នើសុំវគ្គបណ្តុះបណ្តាល និងអប់រំច្បាប់អំពើហិង្សាក្នុងគ្រួសារ យេនឌ័រ សិទ្ធិកុមារ ការជួញដូរកំលាំងពលកម្មកុមារ ជួញដូរស្ត្រី ការរើសអើងស្ត្រីចំនួនសរុប ៣០ ករណី នៅក្នុងឃុំចំនួន ២៦ឃុំ។
- ស្នើសុំវគ្គបណ្តុះបណ្តាលធ្វើជីចិញ្ចឹមសត្វ ការប្រើប្រាស់ថ្នាំគីមី កែច្នៃផ្កា កៅស៊ូ ចំនួនសរុប ១៣ករណី នៅក្នុងឃុំចំនួន ៩ឃុំ និងស្នើសុំពូជស្រូវ កូនឈើ ចំនួនសរុប ១១ ករណី នៅក្នុងឃុំចំនួន ១១ឃុំ។
- ស្នើសុំសាងសង់ផែសម្រាប់ចតទូកដរចម្លងថ្មី ១កន្លែង នៅក្នុងឃុំ ភ្ញីមាសនៃខេត្តកោះកុង និងជួសជុល៣កន្លែង នៅឃុំ កោះជីវាំងនៃខេត្តបាត់ដំបង។
- ការបង្កើតក្រុមសហគមន៍សន្សំ ទេសចរណ៍ ៣ករណី នៅឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។
- ស្នើសុំតបណ្តាញអគ្គិសនី/ទឹកស្អាត ម៉ាស៊ីនភ្លើង/ម៉ាស៊ីនបូមទឹក និងបញ្ចុះតម្លៃទឹក ភ្លើង សរុបចំនួន ២៩ ករណី នៅក្នុងឃុំចំនួន ២៧ឃុំ។
- ការបង្កើតទីផ្សារលក់ផលិតផល ៣ ករណី នៅឃុំបឹងបេង ឃុំគោករមៀត និងឃុំអូរជ្រៅ នៃខេត្តបន្ទាយមានជ័យ។
- ស្នើសុំពូជសត្វវ៉ាក់សាំងសត្វ គ្រូពេទ្យសត្វ ម៉ាស៊ីនកិនស្រូវ គោយន្ត ត្រាក់ទ័រ សរុបចំនួន ២៩ករណី នៅឃុំចំនួន២៧ឃុំ។
- ស្នើសុំឲ្យមានការរក្សាប្រពៃណី ទំនៀមទម្លាប់ជនជាតិ ដូចជាភាសា និងសំភារៈប្រើប្រាស់ជាដើម ១ករណីនៅក្នុងឃុំរម្យទម ស្រុករវៀង ខេត្តព្រះវិហារ។




តំណាងគណបក្សនយោបាយថ្នាក់ឃុំ ដែលបានចូលរួមសិក្ខាសាលា ស្តីពីសម្លេងម្ចាស់ឆ្នោត ក្នុងកាកំណត់តម្រូវការអាទិភាពឃុំដាច់ស្រយាល កំពុងបង្ហាញចំណាប់អារម្មណ៍ចំពោះតម្រូវអាទិភាពទាំង៥។

## ៤.៣.ការសន្យារបស់គណបក្សនយោបាយក្នុងសិក្ខាសាលា

ក្រោយពេលដែលតម្រូវការអាទិភាពត្រូវបានកំណត់ដោយសិក្ខាកាម នៅកំឡុងពេលសិក្ខាសាលា ហើយគ្រប់គណបក្សនយោបាយទាំងអស់ដែលបានចូលរួម បានធ្វើការប្តេជ្ញាចិត្ត ថា និងយកតម្រូវការទាំងនេះទៅអនុវត្តនៅតាមវិធីសាស្ត្រផ្សេងៗគ្នា។ ក្នុងនោះមានបីចំណុចសំខាន់ៗ ដូចជាការសន្យាច្បាស់លាស់ គ្រាន់តែគាំទ្រតែគ្មានការសន្យា និងមិនច្បាស់លាស់។

**ពន្យល់៖**

- ***ការសន្យាច្បាស់លាស់៖*** *សំដៅទៅលើការបេជ្ញាចិត្តរបស់តំណាងគណបក្ស ថានឹងយកតម្រូវការជាអាទិភាពរបស់ម្ចាស់ឆ្នោត ទៅដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ដាក់បញ្ចូលក្នុងកម្មវិធីនយោបាយរបស់គណបក្ស,ដាក់ក្នុងសន្និបាតខេត្ត ផែនការសមាហរណកម្មថ្នាក់ខេត្ត និងសន្យាថា ដោះស្រាយឲ្យបានប្រសិនបើគណបក្សខ្លួនជាប់ឆ្នោត។*
- ***គ្រាន់តែគាំទ្រ តែគ្មានការសន្យា៖*** *សំដៅទៅលើ ចំណាប់អារម្មណ៍ចំពោះតម្រូវការជាអាទិភាព អបអរសាទរ សង្កេតឃ្លាំមើល ធ្វើយ៉ាងណាជម្រុញឲ្យមានការដោះស្រាយ ប៉ុន្តែមិនបានបញ្ជាក់ពីវិធីសាស្ត្រក្នុងដាក់បញ្ចូលតម្រូវការទាំងនេះ ទៅក្នុងកម្មវិធីណាមួយឡើយ។*
- ***មិនច្បាស់លាស់៖*** *សំដៅទៅលើការបង្ហាញពីចំណាប់អារម្មណ៍ តែមិនចំពោះតម្រូវការជាអាទិភាពទាំង៥ នៅក្នុងសិក្ខាសាលា ឬលើកឡើងពីបញ្ហាផ្សេង។*

ខាងក្រោមនេះជាការប្តេជ្ញាចិត្តរបស់សមាជិក**គណបក្សប្រជាជនកម្ពុជា** ៖ មាន៦៨% សន្យាច្បាស់លាស់ ថានឹងយកតម្រូវការអាទិភាពទាំងប្រាំទៅដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ព្រមទាំងដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់គណបក្សខ្លួន(គណបក្ស ប្រជាជនកម្ពុជា) មាន ២៥% គ្រាន់តែគាំទ្រ តែគ្មានការសន្យា និងមាន ៧% មិនច្បាស់លាស់ ចំពោះការគាំទ្រទៅលើតម្រូវការអាទិភាពទាំង៥ បើធៀបទៅនឹងចំនួន ៩៥ សិក្ខាសាលា ដែលមន្ត្រីគណបក្សបានចូលរួម ក្នុងចំណោមសិក្ខាសាលាទាំង១០០ដែលខុមហ្វ្រែលបានរៀបចំ។




ខាងក្រោមនេះ ជាការប្តេជ្ញាចិត្តរបស់សមាជិក**គណបក្សសមរង្ស៊ី** មាន៥៦%សន្យាច្បាស់លាស់ថា នឹងយកតម្រូវការអាទិភាពទាំងប្រាំទៅដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ/សង្កាត់ ព្រមទាំងដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់គណបក្សខ្លួន (គណបក្ស សមរង្ស៊ី) មាន ២៨% គ្រាន់តែគាំទ្រ តែគ្មានការសន្យា និងមាន ១៦% មិនច្បាស់លាស់ ចំពោះការគាំទ្រទៅលើតម្រូវការអាទិភាពទាំង៥ បើធៀបទៅនឹងចំនួន ៦៨ សិក្ខាសាលា ដែលមន្ត្រីគណបក្សបានចូលរួម ក្នុងចំណោមសិក្ខាសាលាទាំង១០០ដែលខុមហ្វ្រែលបានរៀបចំ។



ខាងក្រោមនេះ ជាការប្តេជ្ញាចិត្តរបស់សមាជិក**គណបក្សនរោត្តមរណឫទ្ធិ៖** មាន៧៣% សន្យាច្បាស់លាស់ថា នឹងយកតម្រូវការអាទិភាពទាំងប្រាំទៅដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ព្រមទាំងដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់គណបក្សខ្លួន(គណបក្សនរោត្តមរណឫទ្ធិ ) មាន ៩% គ្រាន់តែគាំទ្រតែគ្មានការសន្យា និងមាន ១៨% មិនច្បាស់លាស់ ចំពោះការគាំទ្រទៅលើតម្រូវការអាទិភាពទាំង៥ បើធៀបទៅនឹងចំនួន ១១សិក្ខាសាលា ដែលមន្ត្រីគណបក្សបានចូលរួម ក្នុងចំណោមសិក្ខាសាលាទាំង១០០ដែលខុមហ្វ្រែលបានរៀបចំ។




ខាងក្រោមនេះជាការប្តេជ្ញាចិត្តរបស់សមាជិក**គណបក្សសិទ្ធិមនុស្ស៖** មាន២៩% សន្យាច្បាស់លាស់ថា នឹងយកតម្រូវការអាទិភាពទាំងប្រាំទៅដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ/សង្កាត់ ព្រមទាំងដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់គណបក្សខ្លួន(គណបក្សសិទ្ធិមនុស្ស ) មាន ៥៧% គ្រាន់តែគាំទ្រ តែគ្មានការសន្យា និងមាន ១៤% មិនច្បាស់លាស់ ចំពោះការគាំទ្រទៅលើតម្រូវការអាទិភាពទាំង៥ បើធៀបទៅនឹងចំនួន ៧សិក្ខាសាលា ដែលមន្ត្រីគណបក្សបានចូលរួម ក្នុងចំណោមសិក្ខាសាលាទាំង១០០ដែលខុមហ្វ្រែលបានរៀបចំ។




ខាងក្រោមនេះ ជាការប្តេជ្ញាចិត្តរបស់សមាជិក**គណបក្សហ្វ៊ុនស៊ិនប៉ិចៈ** មាន៦៣% សន្យាច្បាស់លាស់ថា នឹងយកតម្រូវការអាទិភាពទាំងប្រាំទៅដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ/សង្កាត់ ព្រមទាំងដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់គណបក្សខ្លួន(គណបក្សហ្វ៊ុនស៊ិនប៉ិច ) មាន ១៩% គ្រាន់តែគាំទ្រ តែគ្មានការសន្យា និងមាន ១៨% មិនច្បាស់លាស់ ចំពោះការគាំទ្រទៅលើតម្រូវការអាទិភាពទាំង៥ បើធៀបទៅនឹងចំនួន២៧សិក្ខាសាលា ដែលមន្រ្តីគណបក្សបានចូលរួម ក្នុងចំណោមសិក្ខាសាលាទាំង១០០ដែលខុមហ្វ្រែលបានរៀបចំ។



### ៤.៤.ការជ្រើសរើសអ្នកស្ម័គ្រចិត្តមូលដ្ឋាន

អ្នកស្ម័គ្រចិត្តមូលដ្ឋាន ប្រមាណ **២៨៥** នាក់ ក្នុងនោះ (**៨៤ នាក់**ជាស្ត្រី) ចំនួន នៅកំឡុងពេលធ្វើសិក្ខាសាលា ដោយការជ្រើសរើសនោះ យោងតាមលក្ខខណ្ឌមួយចំនួនដូចជា គឺត្រូវចេះអាន និងសរសេរអក្សរខ្មែរ និងអាចចេះប្រើប្រាស់ការផ្ញើសារតាមទូរស័ព្ទដៃ មានចរិតស្លូតបូត ក្លាហាន អាចមានពេលវេលាធ្វើកិច្ចការងារស្ម័គ្រចិត្ត អព្យាក្រឹត។ ការជ្រើសរើសអ្នកស្ម័គ្រចិត្តមូលដ្ឋាននេះ ក្នុងគោលបំណងតាមដាន និងជម្រុញការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ ឬគណបក្សនយោបាយ ស្របតាមការសន្យា ឬប្តេជ្ញាចចិត្ត កំឡុងពេលសិក្ខាសាលា។

អ្នកស្ម័គ្រចិត្តមូលដ្ឋានក៏នឹងធ្វើការវាយតម្លៃការពេញចិត្ត ឬមិនពេញចិត្តលើការអនុវត្តការសន្យានេះ តាមរយៈ ការប្រមូលពិន្ទុពីប្រជាពលរដ្ឋក្នុងឃុំរបស់ខ្លួន ហើយបញ្ជូនពិន្ទុនេះតាមរយៈ ការផ្ញើសារទូរស័ព្ទដៃ SMS មកកាន់ស្នាក់ការកណ្តាលខុមហ្វ្រែល និងមកវេបសាយ cambodiavotervoice.org។

## ៥-ការផ្សព្វផ្សាយលទ្ធផលសិក្ខាសាលា

បន្ទាប់ពីទទួលបានលទ្ធផលសិក្ខាសាលារួច ខុមហ្វ្រែលបានផ្សព្វផ្សាយតម្រូវការអាទិភាពជាបួនផ្នែកគឺៈ

- ផ្តល់ជូនតំណាងគណបក្សក្នុងឃុំ អ្នកស្ម័គ្រចិត្តមូលដ្ឋានខុមហ្វ្រែល និងប្រជាពលរដ្ឋ។
- ផ្តល់ជូនគ្រប់គណបក្សនយោបាយថ្នាក់ស្រុក និងថ្នាក់ខេត្ត ។
- ផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងនៅលើវេបសាយខុមហ្វ្រែល។
- ផ្សព្វផ្សាយតាមរយៈវិទ្យុ ក្នុងកម្មវិធីសម្លេងសង្គមស៊ីវិល ។

## ៦-ការតាមដាន

អ្នកស្ម័គ្រចិត្តមូលដ្ឋាន និងធ្វើការវាយតម្លៃការពេញចិត្ត ឬមិនពេញចិត្តលើការអនុវត្តន៍ការសន្យានេះ តាមរយៈការប្រមូលពិន្ទុពីប្រជាពលរដ្ឋ ក្នុងឃុំរបស់ខ្លួន ហើយបញ្ជូនពិន្ទុនេះតាមរយៈ ការផ្ញើសារទូរស័ព្ទដៃ SMS មកកាន់ស្នាក់ការកណ្តាលខុមហ្វ្រែល និងមកវេបសាយ cambodiavotervoice.org។

## ៧.ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធ១

### ឈ្មោះ ឃុំ ស្រុក ខេត្ត ដែលបានរៀបចំសិក្ខាសាលា សម្លេងម្ចាស់ឆ្នោតក្នុងឃុំ ដាច់ស្រយាល និងលេខកូដសេចក្តីប្រកាសព័ត៌មាន

| ល.រ | ឃុំ/សង្កាត់ | ស្រុក/ខ័ណ្ឌ | ខេត្ត/រាជធានី | អង្គការ និងសមាគមន៏ចូលរួមសហការ | មតិដែលបានលើកឡើងរបស់គណបក្សនីមួយៗ | | | | | | | | | | | | | | | | | | លេខកូដសេចក្តីប្រកាសព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ការសន្យាច្បាស់លាស់ | | | | | | គ្រាន់តែគាំទ្រ គ្មានការសន្យា | | | | | | មិនច្បាស់លាស់ | | | | | | |
| | | | | | CPP | SRP | NRP | HRP | FUN | | CPP | SRP | NRP | HRP | FUN | | CPP | SRP | NRP | HRP | FUN | | |
| ១ | កោះជីវាំង | បកក្នុំ | បាត់ដំបង | សមាគមយុវជនខ្មែរ | 1 | | | | 1 | | | 1 | | | | | | | | | | | 31 |
| ២ | តាលាស់ | មោងឫស្សី | | សមាគមអាដហុក | | | | | | | 1 | 1 | | | | | | | | | | | 88 |
| ៣ | គោករមៀត | ថ្មពួក | បន្ទាយមានជ័យ | សមាគមអាដហុក, អង្គការទឹកដីសុវណ្ណភូមិ | 1 | 1 | | | 1 | | | | | | | | | | | | | | 63 |
| ៤ | សំបូរ | មង្គលបុរី | | សហគមន៏នេសាទស្រណាល | 1 | | | | 1 | | | | | | | | | | | | | | 33 |
| ៥ | អូរជ្រៅ | អូរបីជាន់ | | សមាគមអាដហុក, អង្គការទឹកដីសុវណ្ណភូមិ | 1 | | | | | | | 1 | | | | | | | | | | | 69 |
| ៦ | បឹងបេង | ម៉ាឡៃ | | សមាគមអាដហុក, សហគមន៍ដើម្បីអភិវឌ្ឍន៍កសិកម្ម | | | | | 1 | | 1 | | | | | | | | | | | | 28 |
| ៧ | ពាមជី | ត្បូងឃ្មុំ | កំពង់ចាម | សមាគមអាដហុក | | | | | | | 1 | | | | | | | | | | | | 67 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | លាំង | | | | | | | | | | | | | | | | | | | | | | |
| ៨ | ជាំ | មេមត់ | | សមាគមអាដហុក | | | | | | | | 1 | | | | | | | | | | | 13 |
| ៩ | ជាំក្រវៀន | មេមត់ | | សមាគមអាដហុក | 1 | | | | | | | | | | | | | | | | | | |
| ១០ | ចាន់មូល | មេមត់ | | សមាគមអាដហុក, និងអង្គការដៃគូអភិវឌ្ឍន៍ | | | | | | | 1 | | | | | | | | | | | | 11 |
| ១១ | ក្រាំងស្គារ | ទឹកផុស | កំពង់ឆ្នាំង | សមាគមអាដហុក, សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម"KKKHRA", និងអង្គការសកម្មភាពដើម្បីបរិស្ថាននិងសហគមន៍ | | | 1 | 1 | | | 1 | | | | | | | | | | | | 26 |
| ១២ | អំពិលទឹក | កំពង់ត្រលាច | កំពង់ឆ្នាំង | សមាគមអាដហុក, សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម "KKKHRA" | 1 | 1 | 1 | 1 | | | | | | | | | | | | | | | 70 |
| ១៣ | សំរោងសែន | កំពង់លែង | កំពង់ឆ្នាំង | សមាគមអាដហុក, សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម"KKKHRA" | 1 | 1 | | | 1 | | | | | | | | | | | | | | 98 |
| ១៤ | ផ្លូវទូក | កំពង់លែង | កំពង់ឆ្នាំង | សមាគមអាដហុក, សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម"KKKHRA", និងអង្គការសកម្មភាពដើម្បីបរិស្ថាននិងសហគមន៍ | 1 | 1 | | | | | | | | | | | | | | | | | 34 |
| ១៥ | ត្រពាំង | ឪព៉ល់ | **កំពង់ស្ពឺ** | សមាគមអាដហុក, សហ | 1 | | | 1 | 1 | | | | | | | | | | | | | | មិនមាន |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ជោរ | | | គមន៍ព្រៃឈើ, និងអង្គការដៃគូរអភិវឌ្ឍន៍ | | | | | | | | | | | | | | | | | | | |
| ១៦ | ដំបូករូង | ភ្នំស្រូច | | សមាគមអាដហុក, អង្គការជីវិតថ្លៃថ្នូរ, និងសហគមន៍ភូមិទឹកល្អក់ | | 1 | 1 | | | | 1 | | | | | | | | | | | | 20 |
| ១៧ | ស្វាយចចិប | បរសេដ្ឋ | | សមាគមអាដហុក | | 1 | | | | | 1 | | | | | | | | | | | | 100 |
| ១៨ | ខ្ទុំក្រាំង | សំរោងទង | | សមាគមអាដហុក | 1 | 1 | 1 | | | | | | | | | | | | | | | | 91 |
| ១៩ | ផាន់ញៀម | | | សមាគមអាដហុក | 1 | | | | 1 | | | | | | | | | | | | | | 79 |
| ២០ | ក្រយា | ប្រាសាទបល្ល័ង្ក | | សមាគមអាដហុក, និងអង្គការទស្សនៈពិភពលោក | 1 | 1 | | | 1 | | | | | | | | | | | | | | 12 |
| ២១ | ដូង | | | សមាគមអាដហុក, និងអង្គការទស្សនៈពិភពលោក | 1 | 1 | | | | | | | | | | | | | | | | | 14 |
| ២២ | កំពង់គោ | កំពង់ស្វាយ | **កំពង់ធំ** | សមាគមអាដហុក, អង្គការទស្សនៈពិភពលោក | 1 | 1 | | | | | | | | | | | | | | | | | 17 |
| ២៣ | នីពេជ | | | សមាគមអាដហុក | 1 | 1 | | | | | | | | | | | | | | | | | 61 |
| ២៤ | ទំរីង | សណ្តាន់ | | សមាគមអាដហុក, និងអង្គការអភិរក្សធនធានធម្មជាតិ | 1 | 1 | | | | | | | | | | | | | | | | | 96 |
| ២៥ | ទឹកវិល | ស្អាង | | សមាគមអាដហុក | 1 | 1 | | | | | | | | | | | | | | | | | 81 |
| ២៦ | ល្វាបម | ថ្មគរ | | សមាគមអាដហុក | | | | | | | 1 | 1 | | | | | | | | | | | 78 |
| ២៧ | ផ្សាដែក | ពញាលឺ | **កណ្តាល** | សមាគមអាដហុក, អង្គការក្រុមប្រឹក្សាយុវជនកម្ពុជា , និង សមាគមឥន្ទ្រទេវី | 1 | | | | | | | 1 | | | | | | | | | | | 55 |
| ២៨ | លើកដែក | កោះធំ | | សមាគមអាដហុក,  សហ | 1 | | | | | | | 1 | | | | | | | | | | | 19 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | គមន៍ព្រៃកជ្រៃដើម្បីការអភិវឌ្ឍន៍ ,និងសមាគមឥន្ទ្រទេវី | | | | | | | | | | | | | | | | | | | |
| ២៩ | ឈើខ្មៅ | | | សមាគមន៍ការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា, សហាគមន៍ព្រៃកជ្រៃដើម្បីការអភិវឌ្ឍន៍, និង សមាគមឥន្ទ្រទេវី | 1 | 1 | | | | | | | | | | | | | | | | | អត់មាន |
| ៣០ | ប្រឡាយ | ថ្មបាំង | កោះកុង | សមាគមអាដហុក, និងសហាគមន៍ព្រៃឈើ | | | | | | | | | | | | | 1 | | | | | | 30 |
| ៣១ | ភ្នីមាស | គិរីសាគរ | | សមាគមអាដហុក, អង្គការយែរ, និងអង្គការដៃគូរអភិវឌ្ឍន៍ | 1 | | | | | | | | | | | | | | | | | | 05 |
| ៣២ | ជ្រោយប្រស់ | កោះកុង | | សមាគមអាដហុក, អង្គការយែរ, និងអង្គការដៃគូរអភិវឌ្ឍន៍ | 1 | | | | | | | | | | | | | | | | | | 06 |
| ៣៣ | កោះកាពិ | | | សមាគមអាដហុក | | | | | | | 1 | 1 | | | | | | | | | | | 85 |
| ៣៤ | ជីខក្រោម | ស្រែអំបិល | | សមាគមអាដហុក | 1 | 1 | | | | | | | | | | | | | | | | | 101 |
| ៣៥ | ស្រែចារ | សំបូរ | ក្រចេះ | សមាគមអាដហុក, បណ្តាញអង្គការសីលកា, សហគមន៍លើកស្ទួយសិទ្ធិដីធ្លីនិងធនធានធម្មជាតិ ,និងអង្គការដៃគូរអភិវឌ្ឍន៍ | 1 | 1 | 1 | | | | | | | | | | | | | | | | អត់មាន |
| ៣៦ | អូរគ្រៀង | | | សមាគមអាដហុក, និងអង្គ | | | 1 | | | | 1 | | | | | | | 1 | | | | | 08 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ការដៃគូរអភិវឌ្ឍន៍ | | | | | | | | | | | | | | | | | | | |
| ៣៧ | កំពង់ចាម | | | សមាគមអាដហុក | 1 | 1 | | | | | | | 1 | | | | | | | | | | 77 |
| ៣៨ | បឹងចារ | | | សមាគមអាដហុក, សហគមន៍ព្រៃឈើ ,និងអង្គការដៃគូរអភិវឌ្ឍន៍ | 1 | | | | 1 | | | 1 | | | | | | | | | | | 04 |
| ៣៩ | ក្បាលដំរី | | | សមាគមអាដហុក | 1 | | | | | | | 1 | | | | | | | 1 | | | | 86 |
| ៤០ | ពីរធ្នូ | ស្នួល | | សមាគមអាដហុក, សហគមន៍លើកស្ទួយសិទ្ធិដីធ្លី | 1 | | | | | | | 1 | | | | | | | | | | | 64 |
| ៤១ | ថ្មី | ចិត្របុរី | | សមាគមអាដហុក, សហគមន៍លើកស្ទួយសិទ្ធិមនុស្ស | | | | | | | 1 | 1 | | | | | | | 1 | | | | 45 |
| ៤២ | ដំរីផុង | ឆ្លូង | | សមាគមអាដហុក, និងសហគមន៍សេដ្ឋ | 1 | 1 | 1 | | | | | | | | | | | | | | | | 68 |
| ៤៣ | កំពង់ដំរី | | | សមាគមអាដហុក | 1 | | | | 1 | | | | | | | | | | | | | | 25 |
| ៤៤ | ស្រែខ្ទុម | កែវសីម៉ា | | សមាគមអាដហុក, អង្គការសរសរទ្រូង, និង អង្គការភូមិខ្ញុំ | 1 | 1 | | | | | | | | | | | | | | | | | 49 |
| ៤៥ | ស្រែហ៊ុយ | កោះញែក | **មណ្ឌលគិរី** | សមាគមអាដហុក, អង្គការសុខភាពគ្មានព្រំដែន(អេចយូ) ,និងអង្គការសេដាក | 1 | | | | | | | | | | | | | | | | | | 38 |
| ៤៦ | រយ៉ | | | សមាគមអាដហុក, និងបណ្តាញសហគមន៍របស់អង្គការសេដាក | 1 | | | | | | | | | | | | | | | | 1 | | 46 |
| ៤៧ | ដាក់ដាំ | អូររាំង | | សមាគមអាដហុក, អង្គការគាំទ្រសហគមន៍ជនជាតិ | | | | | | | 1 | | | | | | | | | | | | 23 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ដើមភាគតិច(ICSO) ,និង អង្គការស្ថានយុត្តិធម៌អន្តរជាតិ(អាយប៊ីជេ) | | | | | | | | | | | | | | | | | | | |
| ៤៨ | រមនា | សែនមនោរម្យ | | សមាគមអាដហុក, អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច(ICSO), និង អង្គការការពារសិទ្ធិមនុស្ស( Vigilance) | 1 | | | | | | | | | | | | | | | | | | 59 |
| ៤៩ | ពូជ្រៃ | ពេជ្រដា | | សមាគមអាដហុក | 1 | | | | | | | | | | | | | | | | | | 87 |
| ៥០ | រមនីយ | | | សមាគមជនជាតិដើមភាគតិចកួយ | | 1 | | | 1 | | 1 | | | | | | | | | | | | 93 |
| ៥១ | រមទម្យ | រវៀង | | សមាគមជនជាតិដើមភាគតិចកួយ | 1 | 1 | | | 1 | | | | | | | | | | | | | | 80 |
| ៥២ | រក្សា | | **ព្រះវិហារ** | សមាគមអាដហុក, អង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍, និងសមាគមជនជាតិដើមភាគតិចកួយ | | 1 | | | | | 1 | | | | 1 | | | | | | | | 54 |
| ៥៣ | ប្រមេរ្តី | | | សមាគមជនជាតិដើមភាគតិចកួយ | | **1** | | | **1** | | **1** | | | | | | | | | | | | **92** |
| ៥៤ | ព្រះឃ្លាំង | ត្បែងមានជ័យ | | សមាគមជនជាតិដើមភាគតិចកួយ | 1 | 1 | | | 1 | | | | | | | | | | | | | | 84 |
| ៥៥ | ពោធិ៍ | | | សមាគមអាដហុក, សមាគមជនជាតិដើមភាគតិចកួយ ,និង សហគមន៍ព្រះ | 1 | | | | | | | | | | | | | 1 | | 1 | 1 | | 58 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ពុទ្ធសាសនាដើម្បីការអភិវឌ្ឍ(BFD) | | | | | | | | | | | | | | | | | | | |
| ៥៦ | កំពង់ស្រឡៅ១ | ឆែប | | សហគមន៍ពន្លកខ្មែរ | 1 | 1 | | | 1 | | | | | | | | | | | | | | 39 |
| ៥៧ | ធ្នា | ជ័យសែន | | សមាគមជនជាតិដើមភាគតិចកួយ | | | | | 1 | | | 1 | | | | | 1 | | | | | | 52 |
| ៥៨ | ព្រីងធំ | ជាំក្សាន្ត | | សមាគមអាដហុក, និងសមាគមជនជាតិដើមភាគតិចកួយ | 1 | | | | | | | | | | | | | 1 | | | | | 65 |
| ៥៩ | ព្រៃកណ្តៀង | ពាមរក៍ | | សមាគមអាដហុក, និងអង្គការដៃគូរអភិវឌ្ឍន៍ | | | | | | | 1 | 1 | | | | | | | | | | | 07 |
| ៦០ | កោះសំពៅ | ពាមជរ | | សមាគមអាដហុក, និងអង្គការដៃគូអភិវឌ្ឍន៍ | 1 | | 1 | | | | | | | | | | | | | | | | 10 |
| ៦១ | ដំរីពូន | ស្វាយអន្ទរ | **ព្រៃវែង** | សមាគមអាដហុក ,អង្គការពន្លឺនៃក្តីសង្ឃឹម(PNKS) , និង អង្គការ (COFAP) | 1 | 1 | | | | | | | | | | | | | | | | | 56 |
| ៦២ | បន្ទាយចក្រី | ព្រះស្តេច | | សមាគមអាដហុក, អង្គការពន្លឺនៃក្តីសង្ឃឹម (PNKS) , និង អង្គការសហការណ៍កាត់បន្ថយភាពក្រីក្រ(ICC) | | | | | | | | 1 | | | | | | | | | | | 74 |
| ៦៣ | រាំងទិល | កណ្តៀង | **ពោធិសាត់** | សមាគមអាដហុក, និង អង្គការវីជីឡែន(VIGILANCE) | 1 | | | | | | | | | | | | | | | | | | 57 |
| ៦៤ | ប្រម៉ោយ | វាលវែង | | អង្គការវីជីឡែន (VIGILANCE) | 1 | | | | | | | | | | | | | | | | | | 75 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៦៥ | អូរសោម | | | អង្គការវីជីឡែន (VIGILANCE) | 1 | | | | | | | | | | | | | | | | | | 41 |
| ៦៦ | ឈើតុំ | ក្រគរ | | អង្គការវិជីឡែន (VIGILANCE) | 1 | | | | | | | 1 | | | | | | | | | | | 36 |
| ៦៧ | ត្បែង | បន្ទាយស្រី | សៀមរាប | សមាគមអាដហុក, អង្គការឆ្លែន, អង្គការសេ ដាក, និងសហគមព្រៃឈើ | 1 | 1 | | | | | | | | | | | | | | | | | 66 |
| ៦៨ | តាសៀម | ស្វាយលើ | | សមាគមអាដហុក, អង្គការលីកាដូ , និងសហគមសន្សំ | 1 | | | | | | | | | | | | | 1 | | | | | 90 |
| ៦៩ | ស្រែណូយ | វ៉ារិន | | សមាគមអាដហុក, អង្គការការពារព្រៃឈើនិងអភិរក្សសត្វព្រៃជលផលកម្ពុជា, និង សហគមន៍ជនជាតិភាគតិចគួយ | 1 | 1 | | | | | | | | | | | | | | | | | 27 |
| ៧០ | ល្វាក្រាំង | | | សមាគមអាដហុក, បណ្តាញអង្គការក្រវ៉ាត់បៃតង , សមាគមកសិករ ,និងសមាគមសន្សំ | 1 | | 1 | | | | | | | | | | | | | | | | 16 |
| ៧១ | ល្វែងឬស្សី | ជីក្រែង | | សមាគមអាដហុក | 1 | 1 | | | | | | | | | | | | | | | | | 15 |
| ៧២ | កំពង់ឃ្លាំង | ស្ទូទនិគម | | សមាគមអាដហុក, និងសហគមនេសាទ | 1 | | | | | | | | | | | | | 1 | | | | | 97 |
| ៧៣ | ញ៉ាង | អណ្តូងមាស | រតនគិរី | សមាគមអាដហុក | | 1 | | | | | 1 | | | | | | | | | | | | 35 |
| ៧៤ | សេដា | លំផាត់ | | សមាគមអាដហុក | | | | | | | | | | | | | 1 | | | | | | 76 |
| ៧៥ | កាឡៃង | | | សមាគមអាដហុក | | | | | | | | | | | | | | 1 | | | 1 | | 24 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៧៦ | ប៉ាតាង | | | សមាគមអាដហុក | 1 | | | | 1 | | | | | 1 | | | | | | | | | 50 |
| ៧៧ | សាមគ្គី | អូរជុំ | | សមាគមអាដហុក | | 1 | | | | | 1 | | | | | | | | | | | | 51 |
| ៧៨ | ប៉ូយ | | | សមាគមអាដហុក | 1 | 1 | | | | | | | | | | | | | | | | | 29 |
| ៧៩ | ប៉ាតេ | អូរយ៉ាដាវ | | សមាគមអាដហុក | 1 | 1 | | | | | | | | | | | | | | | | | 40 |
| ៨០ | បរខាំ | | | សមាគមអាដហុក | | | | | | | 1 | 1 | | | | | | | | | | | 44 |
| ៨១ | យ៉ាទុង | | | សមាគមអាដហុក | 1 | | | | | | | | | | | | | 1 | | | | | 83 |
| ៨២ | លុងឃុង | បរកែវ | | សមាគមអាដហុក | | | | | | | | | | | | | 1 | 1 | | | | | 71 |
| ៨៣ | កិះចុង | | | សមាគមអាដហុក, និង សហគមន៍ព្រៃឈើ | | | | | | | | | | | | | | 1 | | | 1 | | 22 |
| ៨៤ | តាវែងលើ | តាវែង | | សមាគមអាដហុក, និង បណ្ដាញសហគមន៍របស់អង្គការសេដាក | | 1 | | | | | 1 | | | | | | | | | | | | 48 |
| ៨៥ | សេរីមង្គល | កូនមុំ | | សមាគមអាដហុក | 1 | | | | | | | | | | | | | | | | 1 | | 21 |
| ៨៦ | តឹន | | | សមាគមអាដហុក | | | | | | | 1 | | | | | | | | | | | | 82 |
| ៨៧ | ស្រែអង្គ្រង | | | សមាគមអាដហុក | | | | | | | 1 | 1 | | | 1 | | | | | | | | 72 |
| ៨៨ | ស្រែសំបូរ | សៀមប៉ាង | ស្ទឹងត្រែង | សមាគមអាដហុក | | 1 | | | | | | | | | | | | | | | | | 62 |
| ៨៩ | កោះស្រឡាយ | សៀមបូក | | (មិនមាន) | 1 | | | | | | | | | | | | | | | | | | 18 |
| ៩០ | កោះព្រះ | | | សមាគមអាដហុក | | | | | | | | | | | | | 1 | | | | | | 43 |
| ៩១ | ព្រះរំកិល | ថាឡាបរិវ៉ាត់ | | សមាគមអាដហុក | 1 | 1 | | | | | | | | | | | | | | | | | 89 |
| ៩២ | សំអាង | | | សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម (KKKHRA) | 1 | | | | | | | | | | | | | | | | | | 99 |
| ៩៣ | អូរសារាយ | ត្រាំកក់ | **តាកែវ** | សមាគមអាដហុក, និង | 1 | 1 | | | | | | | | | 1 | | | | | | | | 53 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សហាគមន៍អភិវឌ្ឍន៍កសិកម្មអូរសាវាយ | | | | | | | | | | | | | | | | | | | |
| ៩៤ | កំពង់រាប | ព្រៃកប្បាស | | អង្គការអុកស្វាម, និង សហាគមន៍នេសាទ | | | | | | | 1 | 1 | | 1 | | | | | | | | | 37 |
| ៩៥ | ជើងគួន | សំរោង | | សមាគមអាដហុក | 1 | | | | | | | 1 | | 1 | | | | | | | | | 47 |
| ៩៦ | ទ្រាំង | អង្គកែវ | | សហាគមជលផល | 1 | 1 | | | | | | | | 1 | | | | | | | | | 94 |
| ៩៧ | លំទង | អន្លង់វែង | ឧត្តរមានជ័យ | សមាគមអាដហុក | 1 | | | | | | | 1 | | | | | | | | | | | 60 |
| ៩៨ | បេង | បន្ទាយអំពិល | | សមាគមអាដហុក, សហាគមន៍ព្រៃឈើដុងបេង | | | | | | | 1 | | | | 1 | | | 1 | | | | | 33 |
| ៩៩ | ក្រសាំង | ចុងកាល់ | | សមាគមអាដហុក | 1 | | | | | | | | | | 1 | | | | | | | | 42 |
| ១០០ | បាក់អណ្លូង | ត្រពាំងប្រាសាទ | | សមាគមអាដហុក | | 1 | | | | | | | | | | | 1 | | | | | | 95 |
| **សរុប** | **១០០ ឃុំ** | **៧០ ស្រុក** | **១៨ ខេត្ត** | | 65 | 38 | 08 | 02 | 17 | | 24 | 19 | 01 | 04 | 05 | | 06 | 11 | 02 | 01 | 05 | | |

## ឧបសម្ព័ន្ធ២

ខុមហ្វ្រែល COMFREL

# កម្មវិធីសិក្ខាសាលាសម្លេងម្ចាស់ឆ្នោត
# ស្តីពី
# ការកំណត់តម្រូវការជាអាទិភាព ក្នុងឃុំ សង្កាត់ដាច់ស្រយ៉ាល

| ម៉ោង | សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| ៧:៣០-៨:00 | ចុះឈ្មោះសិក្ខាកាម និងវាយតម្លៃមុនសិក្ខាសាលា | ប្រធានក្រុមពិភាក្សាទាំងបី |
| ៨:០០-៨:០៥ | គោរពទង់ជាតិ | អ្នកចូលរួមសិក្ខាសាលា |
| ៨:០៥-៨:១៥ | បង្ហាញពីគោលបំណង កម្មវិធី លទ្ធផលរំពឹងទុក នៃសិក្ខាសាលានិងតួនាទីម្ចាស់ឆ្នោត | អ្នកសម្របសម្រួល លេខា |
| ៨:២០-៨:២៥ | មតិស្វាគមន៍ បើកសិក្ខាសាលា | ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ |
| ៨:២៥-៨:៣៥ | បទបង្ហាញពីសេចក្តីត្រូវការជាអាទិភាពរបស់ឃុំ សង្កាត់ដែលបានមកពីការអង្កេតមុនសិក្ខាសាលា | តំណាងសហគមន៍/អង្គការសង្គមស៊ីវិល |
| ៨:៣៥-៩:៣០ | បទបង្ហាញពីរបៀបកំណត់តម្រូវការជាអាទិភាពក្នុងឃុំ សង្កាត់ និង បែងចែកក្រុមពិភាក្សា **ក្រុមទី១ ក្រុមទី២ ក្រុមទី៣** | អ្នកសម្របសម្រួល |
| ៩:៣០-៩:៤៥ | សម្រាកពិសារអាហារសម្រន់ | លេខាខេត្តខុមហ្វ្រែល |
| ៩:៤៥-១១:០០ | ពិភាក្សាតាមក្រុម | សិក្ខាកាម |
| ១១:០០-១១:៣០ | បង្ហាញតាមក្រុម | តំណាងក្រុម |
| ១១:៣០-១២:៣០ | សម្រាកពិសារអាហារថ្ងៃត្រង់ | |
| ១២:៣០-០១:០០ | បន្តការបង្ហាញតាមក្រុម | តំណាំងក្រុម |
| ០១:០០-០១:៣០ | ការបោះឆ្នោតជ្រើសរើសតម្រូវការជាអាទិភាពទាំង៥ ផ្នែក | សិក្ខាកាមទាំងអស់ |
| ០១:៣០-០១:៤៥ | សម្រាកពិសារអាហារសម្រន់ | |
| ០១:៤៥-០២:០០ | ជ្រើសរើស និងបង្ហាញពីសមាសភាពបណ្តាញ៣នាក់ ចំណាប់អារម្មណ៍(ឈ្មោះ ភូមិ មុខរបរ និងអារម្មស្ម័គ្រចិត្ត) | អ្នកសម្របសម្រួល |
| ០២:០០-០២:១០ | ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តទៅលើតម្រូវការជា អាទិភាពទាំង ៥ ផ្នែក | អ្នកសម្របសម្រួល |

| | | |
|---|---|---|
| ០២:១០-០២:៣០ | ការបំពេញសំណួរក្រោយសិក្ខាសាលា និងការចែកលទ្ធផលដល់សិក្ខាកាម | ក្រុមការងារ |
| ០២:៣០-០២:៥៥ | ការប្រគល់លទ្ធផល និងការថ្លែងចំណាប់ អារម្មណ៍នៃតម្រូវការអាទិភាពទាំង៥ ដល់ក្រុមប្រឹក្សា ឃុំ សង្កាត់ | តំណាងគណបក្សក្នុងឃុំ (ប្រជាជន សមរង្ស៊ី ..........) |
| ០២:៥៥-០៣:០០ | ការថ្លែងបិទសិក្ខាសាលា | អ្នកសម្របសម្រួលខេត្ត |

**ឧបសម្ព័ន្ធ៣**

# ៤-វិធីសាស្រ្ត

## *៤-១-ដំណើរការសិក្ខាសាលា*

សិក្ខាសាលានឹងត្រូវបានរៀបចំសម្រាប់រយៈពេលមួយថ្ងៃ ដែលរួមមានសកម្មភាពសំខាន់ៗ ដូច ជា ការចុះឈ្មោះ ការបើកកម្មវិធីសិក្ខាសាលា ការបង្ហាញពីគោលបំណង បទបង្ហាញទាក់ទងទៅនឹងតម្រូវការជាអាទិភាពនៅក្នុងឃុំ សង្កាត់ ការបែងចែកក្រុម និងពិភាក្សាក្រុម ព្រមទាំងការបោះឆ្នោត ផ្តល់សេចក្តីទុកចិត្ត ទៅលើតម្រូវការជាអាទិភាពទាំង ៥ ។

### *៤-១-១-ការចុះឈ្មោះ ការចែកកញ្ចប់ឯកសារ និងបំពេញសំនួរមុនសិក្ខាសាលា*

ត្រូវរៀបចំកន្លែងចុះឈ្មោះយ៉ាងតិចចំនួន ២កន្លែង ហើយសំនួរមុន និងក្រោយសិក្ខាសាលាក៏ត្រូវបានចែកជូននៅកំឡុងពេលចុះឈ្មោះនោះដែរ ដោយមានដាក់លេខអោយដូចគ្នារួចជាស្រេច។ បានន័យថា បើសិក្ខាកាមចេះអាន និងសរសេរអក្សរ នោះត្រូវប្រគល់សំនួរមុន និងក្រោយសិក្ខាសាលាដែលមានលេខដូចគ្នា (បើសំនួរមុនសិក្ខាសាលាមានលេខ ១ នោះសំនួរក្រោយសិក្ខាសាលាក៏ត្រូវមានលេខ ១ដែរ) ។ បន្ទាប់មកអ្នកចុះឈ្មោះអ្នកចូលរួមត្រូវចែកជូនសិក្ខាកាម នូវកញ្ចប់ឯកសារដែលរួមមាន ប៊ិច និងរបៀបវារៈ ។

**ប្រធានក្រុមសម្របសម្រួលទាំងបីត្រូវទទួលខុសត្រូវក្នុងការចុះឈ្មោះសិក្ខាកាម។**

### *៤-១-២-ការបើកកម្មវិធី*

សិក្ខាសាលានឹងត្រូវបានបើកដោយ ការថ្លែងពីគោលបំណង និងបង្ហាញពីកម្មវិធីព្រមទាំង ដំណើរការសិក្ខាសាលា ដោយអ្នកសម្របសម្រួលខេត្ត ឬលេខាខេត្ត។ បន្ទាប់មក ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវបានអញ្ជើញអោយចូលរួមសិក្ខាសាលា ដើម្បីមានមតិស្វាគមន៍បើកសិក្ខាសាលា។ ចំពោះវាគ្មិនជាតំណាងអង្គការសង្គមស៊ីវិល ឬតំណាងសហាគមន៍ត្រូវធ្វើបទបង្ហាញពីសេចក្តីត្រូវការជាអាទិភាពរបស់ឃុំ សង្កាត់ដែលបានមកពីការស្រាវជ្រាវមុនសិក្ខាសាលា ដើម្បីធ្វើយ៉ាងណាអោយសិក្ខាកាមយល់ដឹងពីតម្រូវការជាអាទិភាពនៅក្នុងឃុំ សង្កាត់ ។

### ៤-១-៣-ការពន្យល់ពីរបៀបកំណត់តម្រូវការជាអាទិភាព និងការបែងចែកក្រុមពិភាក្សា

អ្នកសម្របសម្រួលអង្គសិក្ខាសាលានឹងត្រូវពន្យល់ពីរបៀបកំណត់តម្រូវការជាអាទិភាព ព្រមទាំងធ្វើការបែងចែកក្រុមពិភាក្សាជា៣ ក្រុម ហើយក្រុមនីមួយៗ ត្រូវធ្វើការពិភាក្សាប្រធានបទ ដូចៗគ្នាជុំវិញបញ្ហាដែលជាតម្រូវការជាអាទិភាពនៅក្នុងឃុំ សង្កាត់។

ក្រុមនីមួយៗត្រូវមានសមាជិកយ៉ាងច្រើន ១៦នាក់ ហើយការបែងចែកសិក្ខាកាមតាមក្រុមពិភាក្សា គឺតម្រូវឲ្យសិក្ខាកាមលើកដៃ រាប់ពីលេខ១ ដល់លេខ ៣។ បន្ទាប់មកសមាជិកក្រុមនីមួយៗត្រូវចូលតាមលេខក្រុមរៀងៗខ្លួន។ នៅក្នុងក្រុមនីមួយៗ ត្រូវជ្រើសរើសប្រធានក្រុមម្នាក់ដើម្បីសម្របសម្រួលក្រុមពិភាក្សា ម្នាក់សម្រាប់សរសេររបាយការណ៍ និងម្នាក់សំរាប់ធ្វើបទបង្ហាញពីអ្វីដែលក្រុមបានពិភាក្សា។ សំគាល់ថា ប្រធានក្រុមទាំង៣ ត្រូវជ្រើសរើសចេញពី តំណាងសហគមន៍ ឬ បណ្តាញខុមប្រែ្ល និង CBOs។

### ៤-១-៤-ការពិភាក្សាក្នុងក្រុម

អ្នកសម្របសម្រួលក្នុងក្រុមពិភាក្សាត្រូវមានការយល់ដឹង និងមានការពន្យល់ជាមុនពីដំណើរការពិភាក្សាក្នុងក្រុម ព្រមទាំងពន្យល់ពីគោលការណ៍ពិភាក្សាក្នុងក្រុម។ គោលការណ៍ណែនាំនឹងចែកជូនអ្នកសម្រសម្រួលក្រុម ហើយការពិភាក្សារវាងក្រុមការងារ នឹងធ្វើឡើងមុនថ្ងៃវេទិកាចាប់ ផ្តើម ។

នៅក្នុងក្រុមពិភាក្សានីមួយៗ ត្រូវពិភាក្សាស្វែងរកនូវតម្រូវការជាអាទិភាព ប៉ុន្តែធ្វើយ៉ាងណា សមាជិកក្នុងក្រុមត្រូវបោះឆ្នោតសំរេចចុងក្រោយ យកតែតម្រូវការជាអាទិភាពចំនួន ៥ ប៉ុណ្ណោះ។ ដូច្នេះសរុប ៣ ក្រុមមាន ១៥ តម្រូវការជាអាទិភាព។ នៅក្នុងក្រុមពិភាក្សានីមួយៗ អ្នកសម្របសម្រួល ត្រូវសួរទៅសមាជិកក្រុមទាំងអស់នូវតម្រូវការជាអាទិភាព ទៅនឹងអ្វីដែលប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ត្រូវការជាចាំបាច់ តែចំនុចទាំងអស់នោះត្រូវអោយមានលក្ខណៈច្បាស់លាស់ គឺធ្វើអ្វី? ធ្វើនៅឯណា? ធ្វើចំនួនប៉ុន្មាន? ធ្វើនៅឆ្នាំណា?

### ៤-១-៥-ការបែងចែកតម្រូវការជាអាទិភាពនីមួយៗតាមផ្នែក

បន្ទាប់ពីពិភាក្សារួចហើយ តំណាងក្រុមនីមួយៗ ត្រូវយកលទ្ធផលប្រគល់អោយក្រុមការងារដើម្បីធ្វើការបែងចែកតាមផ្នែក ។ មានន័យថា ការពិភាក្សាមាន ៣ក្រុម ប្រសិនបើក្រុមទីមួយលើកឡើង ទាក់ទងពីការជួលជុលផ្លូវ ហើយក្រុមទី ២ លើកឡើងទាក់ទងទៅនឹងការធ្វើផ្លូវ ដូច្នេះក្រុមការងារត្រូវ បែងចែកដាក់ចំនុចទាំង ២ នេះនៅក្នុងផ្នែក **ផ្លូវ** ។ បើលើកឡើងទាក់ទងទៅនឹងការសាងសង់សាលារៀន និងការជួសជុលសាលារៀន ត្រូវបែងចែកដាក់នៅក្នុងផ្នែក **សាលារៀន** ។

### ៤-១-៦-ការជ្រើសរើសតម្រូវការជាអាទិភាពទាំង ៥ និងការបោះឆ្នោត

បន្ទាប់ពីមានការបែងចែករួចហើយ ក្រុមការងារត្រូវដាក់បង្ហាញតម្រូវការទាំងនោះអោយសិក្ខាកាមទាំងអស់មើល និងអានអោយលឺៗ ។ តម្រូវការជាអាទិភាពអាចមានច្រើនផ្នែក ដូច្នេះតម្រូវអោយសិក្ខាកាមទាំងអស់ធ្វើការជ្រើសរើស ឬធ្វើការបោះឆ្នោតយកតែ ៥ផ្នែកប៉ុណ្ណោះ។ តម្រូវការជាអាទិភាពទាំងអស់ត្រូវសរសេរ

នៅលើក្រដាសធំ ដើម្បីដាក់បង្ហាញសំរាប់អោយសិក្ខាកាមធ្វើការសំរេចចិត្តធ្វើការជ្រើសរើស ដោយសិក្ខាកាមម្នាក់ជ្រើសរើសបានតែ ៥ប៉ុណ្ណោះ ក្នុង ចំណោម ១៥។ សិក្ខាកាមពេលជ្រើសរើសបានតម្រូវការជាអាទិភាពទាំង ៥ ផ្នែក រួចហើយត្រូវសរសេរដាក់នៅលើក្រដាសតូចដែលក្រុមការងារខុមប្រែ្វលចែកជូន។ ពេលដែលសិក្ខាកាមជ្រើសរើស និងសរសេរនៅលើក្រដាសតូចរួចរាល់ហើយ ត្រូវប្រគល់ក្រដាសទៅអោយក្រុមការងារខុមប្រែ្វលដើម្បីធ្វើការបូកសរុបពិន្ទុ។ ក្នុងករណីសិក្ខាកាមណាមិនចេះ អាន និងសរសេរអក្សរ អាចប្រាប់មកក្រុមការងារដើម្បីជួយក្នុងការបោះឆ្នោត។

**ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តទៅលើតម្រូវការជាអាទិភាពទាំង ៥ ផ្នែក ៖** បន្ទាប់ពីបូក សរុបពិន្ទុរួចហើយ ក្រុមការងារខុមប្រែ្វលត្រូវដាក់បង្ហាញតម្រូវការជាអាទិភាពទាំង ៥ ផ្នែក រួចអានអោយឮ ដើម្បីអោយសិក្ខាកាមទាំងអស់បានដឹងពីតម្រូវការជាអាទិភាពទាំង ៥ ផ្នែកដែលទទួលបានពិន្ទុខ្ពស់ជាងគេ។ ក្នុងករណីបើតម្រូវការជាអាទិភាពទី ៥ និងទី ៦ មានសំលេងស្មើគ្នានោះនឹង ត្រូវអោយសិក្ខាកាមធ្វើការបោះឆ្នោតដោយលើកដៃយកចំនុចតែ ១ ក្នុងចំណោមចំនុចទាំង ២ នោះ។ បន្ទាប់មក ពេលទទួលបានតម្រូវការជាអាទិភាពទាំង ៥ ហើយត្រូវអោយសិក្ខាកាមធ្វើ ការបោះឆ្នោត ដោយលើកដៃសំរេចទទួលយកតម្រូវការជាអាទិភាពទាំង ៥។ បើការលើកដៃនោះមានសំលេង៥០ បូក ១នោះ ការបោះឆ្នោតជ្រើសរើសតម្រូវការជាអាទិភាពទាំង ៥ ផ្នែក សំរេចថាបានការ ។ ក្នុងករណី ការបោះឆ្នោតនោះ មិនទទួលបានសម្លេង ៥០ បូក ១ នោះការជ្រើសរើស តម្រូវការជាអាទិភាពត្រូវធ្វើឡើងវិញម្តងទៀត។

**ករណីពិសេសៈ បន្ទាប់ពីការពិភាក្សារួចហើយ បើការបែងចែកចំនុចនីមួយៗដាក់នៅក្នុងផ្នែក ហើយមានតែ ៥ ផ្នែក នោះយើងមិនចាំបាច់ធ្វើការបោះឆ្នោតជ្រើសរើសតម្រូវការជាអាទិភាព ទាំង ៥ ផ្នែកនោះទេ គឺសំរេចបោះឆ្នោតផ្តល់សេចក្តីទុកចិត្តតែម្តង ។ ហើយបើតម្រូវការជាអាទិភាព សិក្ខាកាមជ្រើសរើសមានតែ ៣ ផ្នែក នោះអ្នកសម្របសម្រួលអង្គសិក្ខាសាលាត្រូវបំផុសយ៉ាងណាអោយបាន ២ ផ្នែក (បើអាច) ។**

### *៤-១-៧-ការជ្រើសរើសអ្នកស្ម័គ្រចិត្ត*

ខុមប្រែ្វលនឹងធ្វើការជ្រើសរើសអ្នកស្ម័គ្រចិត្តចំនួន ៣ នាក់ នៅក្នុងឃុំ សង្កាត់ដែលធ្វើសិក្ខា សាលា ហើយលក្ខខណ្ឌនៃការជ្រើសរើសអ្នកស្ម័គ្រចិត្ត គឺត្រូវចេះអាន និងសរសេរអក្សរខ្មែរ និងអាច ចេះប្រើប្រាស់ការផ្ញើសារតាមទូស័ព្ទដៃ មានចរឹតស្លូតបូត ក្លាហាន អាចមានពេល វេលាធ្វើកិច្ចការងារ ស្ម័គ្រចិត្ត អព្យាក្រឹត។

ដំណើរការនៃការជ្រើសរើសអ្នកស្ម័គ្រចិត្ត គឺអ្នកទំនាក់ទំនងស្រុក ឬសកម្មជនខុមប្រែ្វលត្រូវ កំណត់សំគាល់ទុកជាមុន សិក្ខាកាមណាដែលមានលក្ខណៈសម្បត្តិដូចបានរៀបរាប់ខាងលើរួច និងបង្ហាញសមាសភាពទៅអង្គសិក្ខាសាលាបានជ្រាប និងអោយអ្នកទាំងបីថ្លែងពីចំណាប់អារម្មណ៍ផ្ទាល់ ខ្លួន(ឈ្មោះ មកពីភូមិណា មុខរបរ ចំណាប់អារម្មចំពោះការស្ម័គ្រចិត្តនេះ)។

### *៤-១-៨-ការបំពេញសំនួរក្រោយសិក្ខាសាលា និងប្រគល់លទ្ធផលនៃតម្រូវការជាអាទិភាព ទាំង ៥ ដល់វាគ្មិន និងអ្នកចូលរួម*

បន្ទាប់ពីធ្វើការជ្រើសរើសអ្នកស្ម័គ្រចិត្តរួចហើយ ក្រុមការងារខុមហ្វ្រែល ត្រូវអោយអ្នកចូលរួមដែលបានបំពេញសំណួរមុនសិក្ខាសាលា ត្រូវបំពេញសំណួរក្រោយសិក្ខាសាលា ។ កំឡុងពេលដែល សិក្ខាកាមបំពេញសំណួរក្រោយសិក្ខាសាលា ក្រុមការងារត្រូវសរសេរតម្រូវការជាអាទិភាពទាំង ៥ សំរាប់ចែកជូនសិក្ខាកាមទាំងអស់។ នៅពេលដែលសិក្ខាកាមបំពេញសំណួរក្រោយសិក្ខាសាលារួចហើយ ក្រុមការងារខុមហ្វ្រែល ត្រូវចែកលទ្ធផលដល់វាគ្មិន និងសិក្ខាកាមទាំងអស់ ។

**ប្រធានក្រុមនីមួយៗ ត្រូវទទួលខុសត្រូវសរសេរតម្រូវការជាអាទិភាពទាំង៥ សំរាប់កូនក្រុមរបស់ ខ្លួន ដោយប្រើប្រាស់ក្រដាសដាម ដើម្បីធ្វើយ៉ាងណាសរសេរ ១ ដងអោយបាន ៣ ទៅ ៤ សន្លឹក ។**

### *៤-១-៩-ចំណាប់អារម្មណ៍ចំពោះតម្រូវការជាអាទិភាពទាំង ៥ ផ្នែក*

វាគ្មិនដែលជាតំណាងគណបក្សនយោបាយនៅក្នុងមូលដ្ឋាន ត្រូវបានអញ្ជើញចូលរួមសិក្ខាសាលា ដើម្បីថ្លែងចំណាប់អារម្មណ៍ទៅលើតម្រូវការជាអាទិភាពទាំង ៥ ផ្នែក ដែលជាតម្រូវការរបស់សិក្ខាកាមនៅក្នុង ឃុំ សង្កាត់ ។

**ចំណាំ៖** *តម្រូវការអាទិភាពចំនួន៥ ក្នុងឃុំនីមួយៗ នៅក្នុងរបាយការណ៍ស្តីពី សិក្ខាសាលាសម្លេងម្ចាស់ឆ្នោត ក្នុងការកំណត់តម្រូវការជាអាទិភាពនៅ ១០០ឃុំដាច់ស្រយាលនេះ ជាតម្រូវការដែលប្រជាពលរដ្ឋ នៅសហគមន៍ផ្ទាល់បានកំណត់ និងបានស្នើឡើង ហើយតំណាងគណបក្សនៅក្នុងឃុំនីមួយៗ ធ្លាប់បានសន្យាអនុវត្តន៍។ ដូច្នេះខុមហ្វ្រែល សូមឲ្យប្រជាពលរដ្ឋ,ជនជាតិដើមភាគតិច,តំណាងគណបក្សនយោបាយថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ចូលរួមតាមដាន និងវាយតម្លៃទាំងអស់គ្នាចំពោះការអនុវត្តន៍ក្រោយការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២នេះ។*